# ការធ្វើផែនទីធម្មជាតិនៅកម្ពុជាសម្រាប់មនុស្សនិងផែនដី
# សិក្ខាសាលាពិគ្រោះយោបល់អ្នកពាក់ព័ន្ធ

ថ្ងៃទី០៨ - ១១ ខែមិថុនា ឆ្នាំ២០២១ (តាមរយៈ អនឡាញ)

## ១- សេចក្តីផ្តើម

ទិន្នន័យទីតាំងភូមិសាស្ត្រត្រឹមត្រូវស្តីពីស្ថានភាពនិងនិន្នាការនៃជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងសេវាប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ មានសារសំខាន់ចាំបាច់ចំពោះកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និងអង្គភាពស្ថាប័នរាជរដ្ឋាភិបាល។ ក្នុងគោលបំណងធ្វើឱ្យបានសម្រេចការអភិវឌ្ឍន៍ដោយចីរភាព អ្នករៀបចំគោលនយោបាយត្រូវការទិន្នន័យត្រឹមត្រូវនិងច្បាស់លាស់ស្តីពីស្ថានភាព និងនិន្នាការនៃជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងសេវាប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ក៏ដូចជាលទ្ធភាពក្នុងការធ្វើសំយោគព័ត៌មាន ដើម្បីទទួលបានផលពីគោលនយោបាយឱ្យកាន់តែប្រសើរឡើង។ ទ្រឹស្តីនៃការផ្លាស់ប្តូរ គឺផ្អែកលើផែនទីដែលអាចជឿទុកចិត្តបាន ប្រកបដោយព័ត៌មានដែលមានគុណភាពខ្ពស់ មានទំនាក់ទំនងផ្ទាល់ និងមានការផ្សារភ្ជាប់ជាមួយការកសាងសមត្ថភាពនៅថ្នាក់ជាតិទើបនាំទៅដល់ការផ្លាស់ប្តូរ។ ទិន្នន័យកម្រិតសកល មានសារសំខាន់ចំពោះការបង្កើតគោលដៅសម្រាប់ក្របខណ្ឌជីវៈចម្រុះសកលក្រោយឆ្នាំ២០២០ និងវាយតម្លៃវឌ្ឍនភាពរួមឆ្លើយតបនឹងអនុសញ្ញាទីក្រុងរីយ៉ូ និងរបៀបវារៈឆ្នាំ២០៣០។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីដឹកនាំសកម្មភាពនៅលើទីវាល រាជរដ្ឋាភិបាល ត្រូវការព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពជាតិ ដែលអាចប្រើប្រាស់បាន ដើម្បីកំណត់ស្តីពីការគំរាមកំហែង និងអនុវត្តគោលនយោបាយផ្លាស់ប្តូរ ដែលនាំទៅរកដំណោះស្រាយសម្រាប់ធម្មជាតិនិងមនុស្ស។

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និង នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន (DGIS/GDEKI/MoE) កំពុងធ្វើការងារក្នុងភាពជាដៃគូក្នុងការបង្កើនវឌ្ឍនភាពបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ព្រមទាំងបច្ចេកទេសចុងក្រោយបំផុត ដើម្បីពង្រឹងសមត្ថភាពអ្នករៀបចំគោលនយោបាយ ក្នុងគោលបំណងការពារ ស្តារ និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពសម្រាប់មនុស្សនិងផែនដីឱ្យកាន់តែប្រសើរឡើង។ ដោយធ្វើការរួមគ្នាជាមួយនិងក្រុមទីប្រឹក្សាជំនាញឯកទេសវិទ្យាសាស្ត្រ គម្រោងនឹងជួយកម្ពុជាធ្វើផែនទី«**តំបន់សំខាន់ទ្រទ្រង់ជីវិត**»។ **តំបន់សំខាន់** នេះ ត្រូវបានកំណត់ថាជាតំបន់ដែលមានជីវៈចម្រុះសំខាន់ និងផ្តល់សេវាប្រព័ន្ធអេកូឡូស៊ីដល់មនុស្ស ដូចជា ផ្ទុកកាបូន ផ្តល់អាហារ ទឹកសាប កន្លែងចម្រោះទឹក និងជួយកាត់បន្ថយគ្រោះមហន្តរាយ។ **ផែនទីតំបន់សំខាន់ទ្រទ្រង់ជីវិត**

អាចប្រើជាឧបករណ៍គាំទ្រក្នុងការធ្វើសេចក្ដីសម្រេច ដើម្បីជួយដល់អ្នករៀបចំគោលនយោបាយចាត់អាទិភាព ក្នុងការអភិរក្ស ការស្ដារ និង ការគ្រប់គ្រងឱ្យមានចីរភាព ដោយផ្អែកលើសេចក្ដីត្រូវការ និងអាទិភាពជាតិ។ 2/6

វិសាលភាពនៃការងារនេះ នឹងផ្ដោតលើសមាសភាពដូចខាងក្រោម៖

1. *ការដាក់បញ្ចូលគ្នានូវទិន្នន័យជាតិ ដើម្បីបង្កើតទិន្នន័យគោលជីវៈចម្រុះ(biodiversity baseline)៖* គម្រោងនឹងគាំទ្រក្រុមអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីកំណត់ប្រភពទិន្នន័យជាតិ ដែលប្រសើរបំផុត ស្ដីពីជីវៈចម្រុះ បម្រែបម្រួលការប្រើប្រាស់ដី និងសម្ពាធដោយសារមនុស្ស។ គម្រោងនឹងជួយសម្របសម្រួលដើម្បីទទួលបានទិន្នន័យ និងធានាថាទិន្នន័យប្រើប្រាស់នៅក្នុងគម្រោងនេះ មានសុពលភាពសម្រាប់ប្រើប្រាស់ក្នុងការធ្វើសេចក្ដីសម្រេច។

2. *កំណត់អាទិភាពជាតិសម្រាប់ធម្មជាតិ អាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព៖* កម្ពុជានឹងត្រូវបានគាំទ្រ ដើម្បីកំណត់គោលបំណង និងគោលដៅកំពូលរបស់ប្រទេស ព្រមទាំងធ្វើឱ្យមានភាពស៊ីសង្វាក់គ្នានៅក្នុងចំណោមនៃការប្ដេជ្ញាចិត្តនានារបស់ប្រទេសជាតិ ចំពោះអនុសញ្ញាទីក្រុងរីយ៉ូ និងគោលដៅអភិវឌ្ឍន៍ដោយចីរភាព។

3. *ការបង្កើតវិធីសាស្ត្រតាមបែបវិទ្យាសាស្ត្រដើម្បី**កំណត់តំបន់សំខាន់ទ្រទ្រង់ជីវិត**៖* កម្ពុជានឹងត្រូវបានគាំទ្រ ដោយអ្នកជំនាញសកលក្នុងវិស័យផែនការអភិរក្សជាលក្ខណៈប្រព័ន្ធ ដើម្បីបង្កើត**ផែនទីតំបន់សំខាន់ទ្រទ្រង់ជីវិត** ដោយប្រើប្រាស់គម្រូដែលបង្កើតឡើងដោយសមស្រប(tailored models)។

4. *ការសម្រេចថ្នាក់ជាតិត្រូវបានផ្ដល់ព័ត៌មានបានច្រើនជាងមុន៖* រាជរដ្ឋាភិបាលកម្ពុជា នឹងត្រូវបានគាំទ្រក្នុងការវិភាគតាមបែបវិទ្យាសាស្ត្រយ៉ាងហ្មត់ចត់ ដើម្បីកំណត់ **តំបន់សំខាន់ទ្រទ្រង់ជីវិត** នៅក្នុងប្រទេស និងធ្វើសកម្មភាពដោយផ្អែកលើអាទិភាពជាតិ។ ការធ្វើបែបនេះ អ្នករៀបចំគោលនយោបាយនឹងអាចកំណត់បានប្រសើរជាងមុនអំពីហានិភ័យ និងឱកាសពាក់ព័ន្ធនឹងមូលធនធម្មជាតិ និងតំបន់អាទិភាព សម្រាប់កិច្ចការពារ ការស្ដារ និងការគ្រប់គ្រងដោយចីរភាព និងសម្របគោលនយោបាយ និងការសម្រេច ឱ្យឆ្លើយតបនឹងអនុសញ្ញាទីក្រុងរីយ៉ូទាំងបី និងរបៀបវារៈនៃការអភិវឌ្ឍដោយចីរភាព ឆ្នាំ២០៣០ ។

5. *ពង្រឹងការពិនិត្យតាមដាន និងរបាយការណ៍ ដោយផ្អែកលើទិន្នន័យ៖* សមត្ថភាពនឹងត្រូវបានកសាង ដើម្បីធ្វើឱ្យអ្នករៀបចំគោលនយោបាយមានលទ្ធភាពកាន់តែប្រសើរឡើងក្នុងការប្រើប្រាស់ និងវិភាគទិន្នន័យទីតាំងភូមិសាស្ត្រ ដើម្បីពិនិត្យតាមដាន និងរាយការណ៍ស្ដីពីវឌ្ឍនភាពនៃបណ្ដាធាតុទ្រទ្រង់ជីវិត ដើម្បីអនុវត្តក្របខណ្ឌជីវៈចម្រុះសកលក្រោយឆ្នាំ២០២០។

ដោយសារប្រទេសកម្ពុជាសម្បូរជីវៈចម្រុះ និងមានស្រាប់នូវគម្រោងផ្ដួចផ្ដើមនានាជុំវិញជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព កម្ពុជាត្រូវបានជ្រើសរើស ជាប្រទេសអនុវត្តសាកល្បងទី៧ នៅក្នុងគម្រោង «ធ្វើផែនទីធម្មជាតិសម្រាប់មនុស្សនិងផែនដី» ជាមួយនឹង ប្រទេសកូស្ដារីកា យូហ្គង់ដា កាស្សាកស្ថាន ប៉េរូ

កូឡុមប៊ី ហៃទី សាធារណរដ្ឋដូមីនីកកែន អាហ្វ្រិកខាងត្បូង និងអេក្វាឌ័រ។ គម្រោងនេះ នឹងមានកិច្ចប្រជុំរៀបចំណែនាំអ្នកពាក់ព័ន្ធ និងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធចំនួន២លើក នៅក្នុងត្រីមាសទី២ និងត្រីមាសទី៣ ឆ្នាំ២០២១។ ការចូលរួមពីដៃគូមកពីវិស័យនានារបស់ជាតិ ដូចជា ជីវៈចម្រុះ អាកាសធាតុ គ្រប់គ្រងដី ។ល។ គឺជាកិច្ចការដ៏សំខាន់ក្នុងការបង្កើត **ផែនទីតំបន់សំខាន់ទ្រទ្រង់ជីវិត** ដែលបង្ហាញយ៉ាងត្រឹមត្រូវនូវអាទិភាពរបស់កម្ពុជា ដែលអាចជួយពង្រឹងដល់ការធ្វើសេចក្តីសម្រេចលើធម្មជាតិ អាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព ឱ្យមានភាពរឹងមាំ។

កន្លងមក កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ បានរៀបចំធ្វើឡើងដោយ DGIS/GDEKI/MoE និងក្រុមអភិវឌ្ឍន៍ធម្មជាតិរបស់ UNDP នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ និងបានផ្តល់សេចក្តីណែនាំស្តីពីទស្សនៈនៃគម្រោង «ធ្វើផែនទីធម្មជាតិសម្រាប់មនុស្សនិងផែនដី» និងលទ្ធភាពដែលអាចប្រើប្រាស់ផែនទីនេះបាននៅកម្ពុជា ព្រមទាំងបានដាក់នូវធាតុចូលដែលទទួលបានពីអ្នកពាក់ព័ន្ធ ហើយបន្តពីនេះ នឹងត្រូវរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្តីពី «ការធ្វើផែនទីធម្មជាតិសម្រាប់មនុស្សនិងផែនដី»។

## ២- គោលបំណង

សិក្ខាសាលាពិគ្រោះយោបល់នេះ នឹងផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធមកពីស្ថាប័ន នាយកដ្ឋាន និងអង្គភាពនានានៅកម្ពុជា បានពិគ្រោះយោបល់ជាមួយគ្នា ដើម្បីរួមគ្នាកសាងនូវទស្សនវិស័យសម្រាប់គម្រោងស្តីពី «ការធ្វើផែនទីធម្មជាតិសម្រាប់មនុស្សនិងផែនដី»។ អ្នកចូលរួមនឹងសិក្សាជាបឋមស្តីពីគោលបំណងរបស់គម្រោង និងរបៀបនៃការកសាងផែនការអភិរក្សជាលក្ខណប្រព័ន្ធ ដែលនឹងត្រូវផ្តួចផ្តើមធ្វើឡើងតាមរយៈគម្រោងនេះ ដើម្បីបង្កើត ផែនទីតំបន់សំខាន់ទ្រទ្រង់ជីវិតនៅកម្ពុជា។ បន្តពីនេះ សិក្ខាកាម នឹងធ្វើការរួមគ្នា ដើម្បី៖

- កំណត់ការប្តេជ្ញាចិត្តផ្នែកគោលនយោបាយខ្ពស់បំផុតចំនួន១០ ដែលពាក់ព័ន្ធនឹង ធម្មជាតិ អាកាសធាតុ និងការអភិវឌ្ឍន៍ដោយចីរភាព ដែលអាចនឹងរួមបញ្ចូលនៅក្នុង ផែនទីតំបន់សំខាន់ទ្រទ្រង់ជីវិត
- ដាក់ទិន្នន័យជាតិ និងទិន្នន័យពិភពលោក ដែលពាក់ព័ន្ធ ដែលអាចប្រើប្រាស់សម្រាប់កសាងផែនទីនីមួយៗ នៃការប្តេជ្ញាចិត្តខ្ពស់បំផុតទាំង១០ ខាងលើ
- បញ្ជាក់ច្បាស់នូវអ្វីត្រូវការពារ ការគ្រប់គ្រងដោយចីរភាព និងការស្តារ មានន័យយ៉ាងណា នៅក្នុងបរិបទជាតិ
- បន្តពិចារណាពីរបៀបកសាង ផែនទីតំបន់សំខាន់ទ្រទ្រង់ជីវិតចុងក្រោយ តាមរយៈនៃធាតុចូលទាំងនេះ សម្រាប់ការបន្តការផ្តួចផ្តើមបន្ថែមទៀតនៅកម្រិតជាតិ។

ផ្តើមចេញពីព័ត៌មានប្រមូលបានពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ ក្រុមជំនាញភូមិសាស្ត្រអភិវឌ្ឍន៍ធម្មជាតិ របស់ UNDP នឹងកសាង គំរូព្រៀងជាបឋមនូវ ផែនទីតំបន់សំខាន់ទ្រទ្រង់ជីវិតនៅកម្ពុជា ដោយ

បង្ហាញនូវតំបន់គោលដៅដែលត្រូវធ្វើសកម្មភាព ការពារ ការគ្រប់គ្រងដោយចីរភាព និងស្តារធម្មជាតិឡើងវិញ ដែលអាចជួយកម្ពុជា ឱ្យបានសម្រេចការប្តេជ្ញាចិត្តក្នុងការគ្រប់គ្រងធម្មជាតិ។

## ៣- អ្នករៀបចំ

កិច្ចប្រជុំនេះ ត្រូវបានរៀបចំដោយ DGIS/GDEKI/MoE និង ក្រុមអភិវឌ្ឍន៍ធម្មជាតិរបស់ UNDP ដោយមានការជួយសម្របសម្រួលពីលេខាធិការដ្ឋានរេដបូក។

## ៤- កាលបរិច្ឆេទ

ពេលវេលា និងកាលបរិច្ឆេទនៃសិក្ខាសាលាពិគ្រោះយោបល់នេះ នឹងធ្វើឡើងរយៈពេល៤ថ្ងៃ គឺពីថ្ងៃទី០៨ រហូតដល់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ និងមានដំណើរការដូចខាងក្រោម៖

- ផ្នែកទី១ សេចក្តីផ្តើម និងទស្សនវិស័យ
  - ថ្ងៃអង្គារ ទី០៨ ខែមិថុនា ឆ្នាំ២០២១ ម៉ោង ០៩:០០ - ១១:០០ ព្រឹក (Mon, 07 Jun, 22:00-00:00 New York)
  - ថ្ងៃពុធ  ទី០៩ ខែមិថុនា ឆ្នាំ២០២១ ម៉ោង ០៩:០០ - ១២:០០ ព្រឹក (Tue, 08 Jun, 22:00-01:00 New York)
- ផ្នែកទី២ គោលនយោបាយ Hackaton
  - ថ្ងៃព្រហស្បតិ៍ ទី១០ ខែមិថុនា ឆ្នាំ២០២១ ម៉ោង ០៩:០០ - ១២:១៥ ព្រឹក (Wed, 9 Jun, 22:00-01:15 New York)
- ផ្នែកទី៣ ទិន្នន័យ Hackaton និងជំហានបន្ត
  - ថ្ងៃសុក្រ ទី១១ ខែមិថុនា ឆ្នាំ២០២១ ម៉ោង ០៩:០០ - ១២:០០ ព្រឹក (Thu, 10 Jun, 22:00-01:00 New York)

## ៥- ទីកន្លែង

ដោយសារ បញ្ហាកូវីត១៩ អ្នកចូលរួម នឹងត្រូវអញ្ជើញឱ្យចូលរួមតាមអនឡាញ Zoom តាមរយៈលីង https://undp.zoom.us/j/81796439778 ។

## ៦- ភាសា

តាមរយៈ អនឡាញ Zoom មានការបកប្រែបន្តផ្ទាល់ ពីភាសា ខ្មែរ-អង់គ្លេស-ខ្មែរ ។

## ៧- អ្នកចូលរួម

### អង្គភាព-ស្ថាប័នរាជរដ្ឋាភិបាល

- **ក្រសួងបរិស្ថាន**

- អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន (សរុប៦នាក់)
- អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ (សរុប៤នាក់)
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (សរុប៤នាក់)
- អគ្គនាយកដ្ឋានគាំពារបរិស្ថាន (សរុប២នាក់)
- អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន (សរុប២នាក់)

**❖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- រដ្ឋបាលព្រៃឈើ (២នាក់)
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម (៤នាក់)

**❖ ក្រសួងអប់រំ យុវជន និងកីឡា**

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (២នាក់)

**កិច្ចសហការអន្តរជាតិ**

- UNDP (៥នាក់)
- FAO (៣នាក់)
- WCS (៣នាក់)
- WWF (២នាក់)
- GPL-USAID (១នាក់)
- FFI (១នាក់)
- CI (១នាក់)
- Sevir Mekong (២នាក់)
- អ្នកសម្របសម្រួល (២នាក់)
- អ្នកបកប្រែភាសា (២នាក់)